**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៧២៨០/១៣៩ កសក.អល

ថ្ងៃ.ចន្ទ.....៦រោច.....ខែទុតិយាសាឍ ឆ្នាំថោះ.....បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី...០៧.....ខែ...សីហា......ឆ្នាំ២០២៣

**ជម្រាបមក**
**លោកស្រីប្រធានក្រុមហ៊ុន សលីដ វ៉េក់**

**កម្មវត្ថុ ៖** ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យា ស្តីពីការធ្វើបច្ចុប្បន្នភាពគេហទំព័រ និងកម្មវិធីទូរស័ព្ទ បណ្ណាល័យកសិកម្ម របស់មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម។

**យោង ៖** កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់គណៈកម្មាធិការលទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការធ្វើបច្ចុប្បន្នភាពគេហទំព័រ និងកម្មវិធីទូរស័ព្ទ បណ្ណាល័យកសិកម្ម របស់មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម **លោកស្រីប្រធាន** ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មាធិការលទ្ធកម្ម) បានសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនរបស់លោកស្រី ដើម្បីអនុវត្តការងារធ្វើបច្ចុប្បន្នភាពគេហទំព័រ និងកម្មវិធីទូរស័ព្ទ បណ្ណាល័យកសិកម្ម របស់មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ក្នុងតម្លៃទឹកប្រាក់សរុបចំនួន ៣៩ ៨០០ ០០០៛ **(សាមសិបប្រាំបួនលានប្រាំបីរយពាន់រៀលគត់)** ជាតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម **លោកស្រីប្រធាន** ជ្រាបជាព័ត៌មានតាមការគួរ។

សូម **លោកស្រីប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**ចម្លងជូន៖**
-មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម
"ដើម្បីជ្រាប"
-ឯកសារ កាលប្បវត្តិ